00859442

E1/142.2

សាធារណៈ / Public

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ **អៀង សារី** អនុញ្ញាតអោយលោកមេធាវី **អាង ឧត្តម** និង លោកមេធាវី Michael G. KARNAVAS ដែលជាអ្នកតំណាងផ្លូវច្បាប់របស់ខ្ញុំនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ០០២/១៩-០៩-២០០៧-អវតក-អជសដ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងអនុញ្ញាតអោយសមាជិកនានានៃក្រុមមេធាវីការពារក្តីដែលកំពុងធ្វើការងារជាមួយសហមេធាវីរបស់ខ្ញុំ ដើម្បី៖

ក. ទទួលបាន និងប្រើប្រាស់នូវរាល់កំណត់ត្រានៃការពិនិត្យសុខភាពនានាដែលទាក់ទងនឹងលក្ខខណ្ឌសុខភាពពីមុនៗ ដែលខ្ញុំបានទទួលរង ដែលតាមរយៈនេះ ក្នុងឋានៈខ្ញុំជាអ្នកជម្ងឺអាចត្រូវបានគេអនុញ្ញាតអោយប្រើប្រាស់បានផង

ខ. ទទួលបាន និងប្រើប្រាស់នូវរបាយការណ៍វេជ្ជសាស្ត្រដែលចេញដោយវេជ្ជបណ្ឌិតនានានៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលទាក់ទងនឹងលក្ខខណ្ឌសុខភាពរបស់ខ្ញុំនៅពេលដែលខ្ញុំត្រូវបានបញ្ជូនទៅទីនោះ ក្នុងអំឡុងពេលដែលខ្ញុំត្រូវបានឃុំឃាំងនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក

គ. ទទួលបាន និងប្រើប្រាស់នូវរាល់របាយការណ៍ត្រួតពិនិត្យសុខភាពដោយអ្នកជំនាញនានាដែលបង្គាប់ដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដែលទាក់ទងទាំងផ្នែកសុខភាពរាងកាយ និងផ្នែកផ្លូវចិត្តរបស់ខ្ញុំ

ឃ. មានសិទ្ធិផ្តល់នូវឯកសារថតចម្លងនានានៃបណ្តារបាយការណ៍ ដែលមានរៀបរាប់ខាងលើក្នុងផ្នែក ក ដល់ គ ជូនទៅអ្នកជំនាញវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រនានាដែលត្រូវបានជ្រើសរើសដោយអ្នកតំណាងផ្លូវច្បាប់របស់ខ្ញុំ ទោះជានៅក្នុងប្រទេសកម្ពុជា ឬ នៅបរទេសក៏ដោយ និង

ង. ដាក់ជាសាធារណៈនូវរាល់ញត្តិ ទាក់ទងនឹងលក្ខខណ្ឌសុខភាពរបស់ខ្ញុំ និងរបាយការណ៍សុខភាពនានា ដែលបានរៀបចំទាក់ទងនឹងកំណត់ត្រាសុខភាពនានា ដែលយោងទៅតាមអត្ថន័យនៃមាត្រា ៣.១៣ និង ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក (*សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិ.៧*)។

បន្ថែមពីនេះ ខ្ញុំ យល់ព្រមចំពោះការពិភាក្សាជាសាធារណៈនានាលើបញ្ហាសុខភាពរបស់ខ្ញុំនៅក្នុងអំឡុងសវនាការដេញដោលផ្ទាល់មាត់ នាថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ និងការដាក់បង្ហាញជាសាធារណៈនានានូវរបាយការណ៍នានា របស់វេជ្ជបណ្ឌិត John Campbell និងកំណត់ត្រាសុខភាពនានា។

ស្នាមមេដៃ:  ____________________ កាលបរិច្ឆេទ: 8 វិច្ឆិកា 2012